Minnesota Department of Health • ព័ត៌មានការពិតអំពីប្រភេទរោគ 10/11/2005

# Botulism

## តើបុតុលីសឹមជាអ្វី?

បុតុលីសឹម វាជាជំងឺធ្ងន់ដល់ជីវិត ដែលបណ្ដាលមកពីបែប ពុលម្យ៉ាង។ ពុល- ដែលគេស្គាល់ ថា បុតុលីសឹម តក់ហ្ស៊ីន- បានបង្កើតដោយ បាក់តេរីម្យ៉ាង។ ជាតិពុល បុតុលីសឹម ជាជាតិពុលដ៏ខ្លាំងបំផុត ដែលពួកវិទ្យាសាស្ត្រស្គាល់។



*អាហារធ្វើនៅផ្ទះ ច្រកដបទុក ដែលមានមេរោគបូតូលីសឹម*

បុតុលីសឹម ដែលគេតែងតែគិតថា ជាភាពអាសន្នផ្នែកខាងពេទ្យ។ វា អាចបណ្ដាលឲ្យស្លាប់ ដោយធ្វើឲ្យសសៃដកដង្ហើមរបស់មនុស្សស្លាប់។ ក៏ប៉ុន្តែ ជាង៣០ឆ្នាំកន្លងទៅ ដោយមានការថែរទាំប្រសើរជាងមុន ល្បឿន នៃការស្លាប់នឹងបុតុលីសឹម បានបន្ថយពី ៥០ទៅ៨ភាគរយ។

តាមកំរិតធម្មតា ប្រហែល១១០សំណុំរឿងនៃបុតុលីសឹម បានរាយការណ៍ រៀងរាល់ឆ្នាំនៅក្នុងសហរដ្ឋ។

## តើអ្នកឆ្លងបុតុលីសឹមតាមរបៀបណា?

តាមធម្មតា មនុស្សអាចឆ្លងបុតុលីសឹមតាមពិធី៣ផ្សេងៗគ្នា ដូចជា:

- ដោយញ៉ាំអាហារដែលមានជាតិពុល។
- ពីជាតិពុល ដែលបានបង្កើតឡើងនៅពេលដំបៅមានបាក់តេរីចូល។
- ពេលដែលទារកញ៉ាំ រឺផឹកអ្វីដែលមានស្ពបាក់តេរី-បែបស្នូករឹង ដែលបាក់តេរីប្រែ នៅពេលបាក់តេរីមិនអាចធំធាត់ និងបង្ករ បង្កើតចំនួនបាន។

ក៏បានជឿតទៀតថា ជាតិពុលបុតុលីសឹម អាចយកមកប្រើជាអាវុធមួយ- ដោយដាក់វាក្នុងអាហារ រឺដោយបញ្ចេញទៅក្នុងខ្យល់អាកាស ដើម្បីឲ្យមនុស្សដកដង្ហើមចូល។

## តើអ្វីខ្លះដែលជារោគសញ្ញា?

រោគសញ្ញានៃបុតុលីសឹម មានដូចគ្នាទាំងអស់ មិនថាតើ មនុស្សបានឆ្លងវា តាមវិធីណាក៏ដោយ។ វាមានបញ្ហូលទាំង មើលអ្វីៗទៅឃើញរូបពីរ ភ្នែកមើលព្រឹលៗ ត្របកភ្នែកធ្លាក់ចុះ និយាយមិនសូវច្បាស់ ពិបាកលេបអាហារ ស្ងួតមាត់ និងខ្សោយកម្លាំងសាច់ដុំ។ ទារកដែលមានបុតុលីសឹម មើលឃើញទៅដូចជាល្ហិតល្ហៃ មិនញ៉ាំអាហារគ្រប់គ្រាន់ មានលាមករឹង យំខ្សោយ និងសរសៃសាច់ដុំមិនរឹងមាំ។ ទាំងអស់នេះជារោគសញ្ញាស្លាប់សរសៃ ដែលបណ្ដាលមកពីពីសពុល។ បើគ្មានការព្យាបាលទេ មនុស្សដែលមានបុតុលីសឹម អាចនឹងមានការស្លាប់ដៃ ជើង ដងខ្លួន និងសាច់ដុំដែលប្រើសំរាប់ដកដង្ហើម។
ពេលបុតុលីសឹមបណ្ដាលមកពីអាហារដែលមានជាតិពុលនោះ រោគសញ្ញាទាំងនេះ ធម្មតាបង្ហាញឲ្យឃើញក្នុងរវាង១៨ទៅ៣៦ម៉ោង។ ក៏ប៉ុន្តែ វាអាចចាប់ផ្តើមនៅពេល៦ម៉ោងក្រោយមក រឺ១០ថ្ងៃក្រោយមក។

## តើអាចឲ្យអ្នកឆ្លងបុតុលីសឹមពីមនុស្សឯទៀតបានទេ?

ទេ។ម្តងទៀត បុតុលីសឹមជាបែបពុលម្យ៉ាង។ វាមិនបណ្ដាលមកពីសត្វមានជីវិតទេ ហើយវាក៏មិនអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានដែរ។

## តើអាចព្យាបាលបុតុលីសឹមបានទេ?

ការថែរទាំល្អិតល្អន់នៅក្នុងមន្ទីរពេទ្យធំ គឺជាការព្យាបាលដ៏សំខាន់សំរាប់គ្រប់បែបនៃបុតុលីសឹម។ នោះរាប់ទាំងពិធីទាំងឡាយដែលបង្កើតឡើងសំរាប់ជួយដល់អ្នកជម្ងឺឲ្យដកដង្ហើមបាន។ ប្រសិនបើជម្ងឺបានសំគាល់ឃើញយ៉ាងឆាប់រហ័សនោះ មានថ្នាំសំរាប់ទប់កុំឲ្យមានលទ្ធផលនៃការកើតឡើងរបស់បុតុលីសឹម-ប៉ុន្តែថ្នាំទាំងនោះ មិនអាចយកមកប្រើដើម្បីព្យាបាលទារកបានឡើយ។ មានវិធីដើម្បីបំបាត់ជាតិពុលពីអាហារ ដែលនៅក្នុងប្រព័ន្ធនៃការរំលាយអាហាររបស់អ្នកជម្ងឺ។ នៅពេលមនុស្សបានកើតបុតុលីសឹមពីដំបៅ ប្រភពនៃជាតិពុលអាចត្រូវវះកាត់យកចេញបាន។

MINNESOTA MDH DEPARTMENT OF HEALTH
Communications Office
625 North Robert Street/Box 64975
St. Paul, MN 55164-0975
(651) 201-4989
www.health.state.mn.us

ក្នុងសំនុំរឿងដ៏ធ្ងន់ ការសះស្បើយឡើងវិញពីបុតុលីសឹម អាចអស់រយះពេលរាប់អាទិត្យ រឺរាប់ខែ។ ឥទ្ធិពលបន្ទាប់មក ដែលបណ្តាលមកពីបុតុលីសឹម រាប់ទាំងការហេវហត់ និងពិបាកដកដង្ហើម-អាចអស់រយះពេលរាប់ឆ្នាំ។

## តើអាចការពារកុំឲ្យមានបុតុលីសឹមបានទេ?

គ្មានថ្នាំការពារ ដើម្បីការពារបណ្តាជន ប្រឆាំងនឹងបុតុលីសឹមទេ។ ថ្នាំការពាពិសោធ ជួនកាល ត្រូវបានប្រើដើម្បីការពារអ្នកដកការពិសោធនិងពួកទាហាន។ បុតុលីសឹមដែលទាក់ទងខាងអាហារ អាចការពារបានដោយការប្រុងប្រយ័ត្ននឹងការធ្វើម្ហូបអាហារ – ម្ហូបកំប៉ុងដែលធ្វើខ្លួនឯងវាជាប្រភពនៃការព្រួយបារម្ភដ៏ធំមួយ។ ទារកដែលនៅក្រោមអាយុ១២ខែមិនត្រូវឲ្យវាញ៉ាំទឹកឃ្មុំ ដែលអាចមានស្ព៍នៃបាក់តេរីបុតុលីសឹម។

## ហេតុអ្វីបានជាគេគឹតថាបុតុលីសឹមជាអាវុធសាហាវមួយ?

ជាតិពុល ដែលបង្កើតដោយបាក់តេរីបុតុលីសឹម វាមានកម្លាំង និងឥទ្ធិពលខ្លាំង។ ជាតិពុលនេះ វាងាយស្រួលក្នុងការបង្កើតនិងនាំយកពីកន្លែងមួយទៅកន្លែងមួយទៀត។ ហើយមនុស្សដែលកើតបុតុលីសឹម ត្រូវតំរូវឲ្យមានការព្យាបាលដ៏យូនិងល្អិតល្អន់។ ការកើតឡើងយ៉ាងទាន់ហន់នៃបុតុលីសឹម អាចមានការរំខានដ៏ធំមួយដល់សកម្មភាពដែលមានជាធម្មតា។

ការប៉ុនប៉ងប្រើបុតុលីសឹមជាអាវុធ តាំងតែពីសង្គ្រាមលោកលើកទី២។ តាំងពីឆ្នាំ១៩៧០ ប្រជាជាតិមួយចំនួនបានបង្កើតឡើង រឺជាថាកំពុងបង្កើតវា-សមត្ថភាពនឹងប្រើបុតុលីសឹមជាអាវុធ។ សាសនាជប៉ុនមួយក្រុមបានសាកបញ្ចេញជាតិពុលទៅលើអាកាសនៅកន្លែងជាច្រើនក្នុងតំបន់ក្រុងតូក្យូ យ៉ាងហោចណាស់៣ដង រវាងឆ្នាំ១៩៩០និង១៩៩៥។

## តើគួរឲ្យអ្វីប្រសិនបើខ្ញុំបានគឹតថា ខ្ញុំប្រហែលមានបុតុលីសឹម?

ប្រសិនបើអ្នកមានរោគសញ្ញាបុតុលីសឹម សូមទៅជួបបណ្ឌិតរបស់អ្នកភ្លាម។ សូមទាក់ទងមកក្រសួងសមត្ថកិច្ចតំបន់របស់អ្នក ប្រសិនបើអ្នកឃើញកាលះគេសះ រឺសកម្មភាពសង្ស័យនៅក្នុងសហគមន៍របស់អ្នកដែលទាក់ទងនឹងការប្រើបុតុលីសឹម-រឺគ្រឿងពុលឯទៀត-ជាអាវុធ។